# ការសំភាសន៍របស់លោកពូ ធន់ ថេត

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ ធន់ ថេត

<u>ការសង្ខេបប្រវត្តិរបស់ លោកពូ ធន់ ថេត</u>

លោកពូ ធន់ ថេត មានអាយុ54ឆ្នាំ នៅក្នុងឆ្នាំ2018 លោកពូ ធន់ ថេត មានភេទប្រុស លោកពូ ធន់ ថេត មានទីលំនៅបច្ចុប្បន្ននៅ ភូមិស្ទឹងជ្រៅ ឃុំផ្សារដើមមាន ក្រុងតាខ្មៅ ខេត្តកណ្តាល។

កៈ ចឹងជាដំបូងខ្ញុំអរគុណពូដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ពូ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍ពូ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់ពូយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេពូ?

ខៈ បាទមានអីទេព្រមតើក្មួយ

កៈ បាទពូបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍ពូគឺនៅថ្ងៃទី6ខែ4 ឆ្នាំ2018 គឺធ្វើនៅនឹងភូមិអីគេដែរពូ?

ខៈ ភូមិស្ទឹងជ្រៅ ឃុំដើមមាន ក្រុងតាខ្មៅ

កៈ អូ៎!!នៅនឹងគេហៅក្រុងតាខ្មៅចឹងតែម្តងនឹងហោសពូ ហើយនឹងខេត្តកណ្តាលណាពូណា?

ខៈ បាទនឹងហើយខេត្តកណ្តាល

កៈ បាទពូ ចឹងសំរាប់ពូមានឈ្មោះពេញរបស់ពូនឹងមានឈ្មោះអីគេដែរពូ?

ខ៖ ខ្ញុំមានឈ្មោះធន់ ថេត

ក៖ ចុះមានឈ្មោះហៅក្រៅទេពូ?

ខ៖ អត់មានទេមានឈ្មោះតែមួយនឹងហាស

ក៖ អូ!!ចុះដូចជាកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះពូអីផ្សេងទៀតទេនឹងពូ?

ខ៖ ថាពាក្យលេងសើចនឹងអត់មានដែរខ្ញុំ

ក៖ ប៉ុន្តែធ្លាប់មាននរណាហៅរឺមិត្តភក្តិហៅឈ្មោះលេងសើចអីចឹងហាសពូ?

ខ៖ មានដែរគេហៅអាគម រឺអាឆ្អឹងអីចឹងទៅ

ក៖ អូ!!បាទពូចុះសំរាប់ពូសព្វថ្ងៃនឹងពូអាយុប៉ុន្មានដែរទៅពូ?

ខ៖ ខ្ញុំសព្វថ្ងៃនឹងខ្ញុំអាយុ54ឆ្នាំហើយនឹង

ក៖ ចឹងពូអាយុ54ឆ្នាំចុះពូមានដឹងថាពូកើតនៅថ្ងៃខែឆ្នាំណាពូមានចងចាំទេ?

ខ៖ ខ្ញុំដូចជាភ្លេចដែរនឹងហាសបើមិនឆ្នាំ1964-1965ខ្ញុំបានភ្លេចដែរនឹង
ខ្ញុំអត់បានមើលបញ្ជីជាតិនឹង

ក៖ អូ!!ចឹងពូកើតនៅឆ្នាំ1964ពូ?

ខ៖ បាតចឹងហោស

ក៖ ចុះសំរាប់ថ្ងៃខែពូមានចងចាំទេ?

ខ៖ ខ្ញុំអត់បានចងចាំផងនឹង

ក៖ ចុះសំរាប់ឆ្នាំច័ន្ទគតិហាសពូមានដឹងថាពូកើតឆ្នាំអីគេដែរទេ លក្ខណះឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖ ខ្ញុំកើតនៅឆ្នាំរោង

ក៖ ចឹងពូនៅឆ្នាំរោងណាពូ ចុះពូកើតនៅថ្ងៃខែឆ្នាំណាពូមានចងចាំទេ?

ខ៖ អត់បានចងចាំផងខ្ញុំ

ក៖ អូ!!សំរាប់ពូកើតនៅណាដែរពូមានចងចាំទេ?

ខ៖ ខ្ញុំបានកើតនៅខាងវាលល្បងហោស នៅស្រុកពាមចរ ខេត្តព្រៃវែង

ក៖ អូ!!ចុះឃុំអីគេដែរពូនៅណុង?

ខ៖ នៅឃុំអង្គរអង្គ

ក៖ ចុះភូមិវិញពូ?

ខ៖ នៅភូមិវាលល្បង

ក៖ ភូមិវាលល្បង ចុះស្រុកវិញពូ?

ខ៖ នៅស្រុកពាមចរ ខេត្តព្រៃវែង

ក៖ ស្រុកពាមចរ ខេត្តព្រៃវែង ចុះពូមានបងប្អូនចំនួនប៉ុន្មាននាក់ដែរពូ?

ខ៖ ខ្ញុំមានបងប្អូនចំនួន7នាក់នឹង

ក៖ ចុះពូជាកូនទីប៉ុន្មានដែរពូ?

ខ៖ ខ្ញុំជាកូនទី7តែម្តងនឹង

ក៖ អូ!!ចឹងពូកូនពៅគេហោសពូ?

ខ៖ បាទនឹងហើយ

ក៖ ចុះបងប្អូនរបស់ពូនឹងមានស្រីប៉ុន្មាននឹងប្រុសប៉ុន្មាននាក់ដែរទៅពូ?

ខ៖ បងប្អូនរបស់ខ្ញុំនឹងមានស្រី3នាក់នឹងប្រុស4នាក់

ក៖ ចុះសំរាប់ពូប៉ុន្តែបងប្អូនរបស់ពូនឹងនៅរស់សព្វថ្ងៃទាំងអស់គ្នាដែរទេណាពូ?

ខ៖ អើរស្លាប់អស់ខ្លះហើយនឹងស្លាប់អស់3នាក់ហើយនឹង

ក៖ ចុះអ្នកដែរស្លាប់នឹងពួកគាត់ជាបងទីប៉ុន្មានដែរទៅពូ?

ខ៖ មានបងទី1នឹងបងទី3 នឹងបងទី4

ក៖ អូ!!ប៉ុន្តែកើតអីបានជាពួកគាត់ស្លាប់ដែរពូ
ស្លាប់នៅពេលជំនាន់ពលពតរឺយ៉ាងម៉េចដែរពូ?

ខ៖  គាត់ស្លាប់ដោយសារតែឈឺជំងឺដោយខ្លួនឯងទេមិនមែនដោយគេធ្វើបាបអីគាត់ទេនឹង

ក៖  ចឹងមានន័យថាបងប្អូនរបស់ពូនឹងរួចពីពលពតទាំងអស់គ្នា?

ខ៖  បាទរួចពីពលពតហើយនឹង

ក៖
ប៉ុន្តែសំរាប់គាត់មានឈ្មោះអីបងរបស់ពូរហូតមកដល់ពូចឹងហាសពូមានចងចាំឈ្មោះពួកគាត់ដែរទេ?

ខ៖  ខ្ញុំចងចាំបងទី1នឹងមានឈ្មោះថៃ បងទី2គាត់ឈ្មោះថន់
បងទី3ស្រីគាត់មានឈ្មោះតាំង ទី4គាត់មានឈ្មោះបងវណ្ណី ទី5ហេរាប់ច្រឡំទេហីទី5
ហេរាប់ច្រឡំហើយទី1ឈ្មោះបងថៃ ទី2មានឈ្មោះបងថន់ ទី3មានឈ្មោះថាត
ទី4នឹងមានឈ្មោះបងតាំង ទី5និងឈ្មោះបងវណ្ណី ទី6នឹងឈ្មោះបងវណ្ណា

ក៖  ចឹងទី7នឹងពូណា?

ខ៖  ទី7ខ្ញុំនឹងបាទ

ក៖  អូ្!!បាទពូចុះពូមានចងចាំអនុស្សាវរីយ៍អីកាលពីពូនៅក្មេងៗៗហាស
នៅក្មេងៗៗនឹងពូធ្លាប់បានលេងអីជាមួយគ្នាដែរទេដូចលក្ខណៈលេងបិទពួន
លេងឡឹកបាយឡអីចឹងហាសពូមានទេ?

ខ៖  ធ្លាប់លេងដែរនឹង

ក៖  ចុះលេងអីគេខ្លះដែរទៅពូ?

ខ៖  លេងបិទពួនលេងដេញគ្នា
មុជទឹកលេងអីចឹងទៅបងៗៗរបស់ខ្ញុំនឹងអោយខ្ញុំដេញគាត់អីចឹងទៅ

ក៖  អូ្!!បាទពូបាទអាងតែពូក្មេងជាងគេហោសពូ?

ខ៖
បាទអាងតែខ្ញុំតូចជាងគេជួននឹងខ្ញុំនៅលើទូកចឹងទៅគាត់មុជទឹកនៅក្រោមទូកចឹងទៅអោយខ្ញុំចាំចាប់ គាត់រីអោយខ្ញុំចាំវៃគាត់ចឹងហាស

ក៖  អូ្!!ពូនៅខាងស្រុកទន្លេមែនទេពូ?

ខ៖  ខ្ញុំនៅស្រុកទន្លេកាលពីមុនមកនឹងខ្ញុំនៅតូចៗៗនឹង

ក៖  ចឹងមានន័យថាខាងបងប្អូនរបស់ពូនឹងសុទ្ធតែចេះហែលទឹកទាំងអស់គ្នាហើយណាពូ?

ខ៖  បាទចេះតើ!!

ក៖  ចុះពូមានលក្ខណះថាធ្លាប់ទៅស្រែអីជាមួយបងប្អូនរបស់ពូទេ?

ខ៖  បាទពីចូលលុនណុលនឹងខ្ញុំទៅនៅស្រុកស្រែនឹងជាប់រហូតទាល់តែពលពតនឹង

ក៖  ប៉ុន្តែពូមានចងចាំថាពូធ្លាប់មានអនុស្សាវរីយ៍អីគេទេកាលនៅស្រុកស្រែចឹងហាសពូ?

ខ៖  ហ៉ោ!!ធ្វើស្រែធ្វើស្រូវអីជាមួយបងៗៗរបស់ខ្ញុំនឹងហាស

ក៖  អូ៎!!ចឹងទេណាពូ?

ខ៖  បាទកាលណុងខ្ញុំនៅតូចជាងគេ
ចឹងខ្ញុំជាអ្នកភ្ជួរចឹងទៅហើយបងៗៗអ្នកស្ទូងអីចឹងទៅណាស់

ក៖  អូ៎!!បាទពូបាទ ចុះពូចូលចិត្តលេងអីគេជាមួយបងប្អូនរបស់ពូដែរ?

ខ៖  ច្រើនតែលេងមុជទឹកដេញគ្នាលេងចឹងទៅ

ក៖  អូ៎!!បាទពូបាទ ចុះបងរបស់ពូដែរពួកគាត់នៅរស់សព្វថ្ងៃនឹងពួកគាត់នៅណាវិញពូ?

ខ៖  គាត់នៅឯខាងខេត្តព្រៃវែងហោស

ក៖  នៅព្រៃវែងទាំងអស់គ្នាតែម្ដងនឹងហោសពូ?

ខ៖  បាទនៅណុង

ក៖  ចឹងមានតែពូទេនៅនឹងមែនទេពូ?

ខ៖  បាទមានតែខ្ញុំទេនៅនឹង

ក៖
ប៉ុន្តែដូចជាបងរបស់ពូគាត់ធ្វើអីគេដែរនៅណុងហាសពូសំរាប់ចិញ្ចឹមក្រុមគ្រួសារចឹងហាស?

ខ៖  គាត់គ្មានធ្វើអីទេគាត់ធ្វើតែស្រែធ្វើអីចឹងទៅ

កៈ ទាំងអស់គ្នាតែម្តងនឹងហោសពូ?

ខៈ បាទ!!នឹងហើយ

កៈ អូ៎!!បាទចឹងសំរាប់ឪពុករបស់ពូនឹងគាត់មានឈ្មោះអីគេដែរទៅពូ?

ខៈ ឪពុករបស់ខ្ញុំនឹងគាត់មានឈ្មោះខន

កៈ ប៉ុន្តែគាត់នៅរស់សព្វថ្ងៃដែរតើហីពូ?

ខៈ គាត់ស្លាប់ហើយនឹងគាត់ស្លាប់តាំងពីឆ្នាំ1984នឹង

កៈ អូ៎!!រហូតមកដល់ឥឡូវនឹងគាត់ប្រហែលជាអាយុប៉ុន្មានដែរពូមានចងចាំទេ?

ខៈ បើនិយាយពីអាយុពិតគាត់មកនឹងប្រហែលជាអាយុ100ឆ្នាំហើយមើលទៅ

កៈ អូ៎!!ចឹងហោសពូ?

ខៈ ពីព្រោះអីគាត់ស្លាប់តាំងពីឆ្នាំ1984ហើយគាត់អាយុ70ឆ្នាំនឹង

កៈ អូ៎!!អាយុ70ឆ្នាំនៅឆ្នាំ1984ចឹងគាត់អាយុ100ឆ្នាំជាងនឹងពូ?

ខៈ អូ៎!!បាទនឹង

កៈ អូ៎!!សំរាប់ឪពុករបស់ពូនឹងគាត់កើតនៅណាដែរពូមានចងចាំទេ?

ខៈ គាត់កើតនៅយើងស្រុកកណ្តាលស្ទឹងនឹងហាស

កៈ នៅស្រុកកណ្តាលស្ទឹងអូនៅខេត្តកណ្តាលយើងនឹងហោសពូ?

ខៈ បាទនឹងហើយស្រុកកំណើតរបស់គាត់នឹងគាត់នៅនឹង

កៈ អូ៎!!បាទពូ ចុះសំរាប់ម្តាយរបស់ពូនឹងគាត់មានឈ្មោះអីគេដែរពូ?

ខៈ ឈ្មោះគាត់នឹងមានឈ្មោះគត់

កៈ គាត់មានឈ្មោះគត់
ចុះម្តាយរបស់ពូបើមកដល់ឥឡូវនឹងគាត់ប្រហែលជាអាយុប៉ុន្មានដែរទៅពូ?

ខៈ ប្រហែល

កៈ គាត់អាយុប្អូនតាប៉ុន្មានឆ្នាំដែរទៅពូ?

ខៈ គាត់អាយុប្អូនតា7ឆ្នាំនឹងគាត់ស្គរសម្តេចសីហានុហោស

កៈ ចឹងមានន័យថាគាត់អាយុក្បែរ100ឆ្នាំហើយណាពូ?

ខៈ បាទគាត់អាយុក្បែរ100ឆ្នាំហើយនឹងគាត់ប្រហែលជាកៅជាងអីហើយនឹង

កៈ បាទពូ ចុះសំរាប់គាត់កើតនៅណាដែរពូមានចងចាំទេ?

ខៈ គាត់កើតនៅស្រុកកណ្តាលស្ទឹងនឹងដែរនឹង?

កៈ អូ៎!!ម៉េចបានពូផ្លាស់ទៅនៅព្រៃវែងដែរពូ?

ខៈ គាត់កាលពីមុនមកគាត់ចេញដើររកស៊ីដូចតែខ្ញុំចឹងដែរនឹង
ដល់ពេលហើយៗគាត់ក៏នៅណុងតែម្តង
នឹងហាសកើតសង្គ្រាមចឹងទៅគាត់ក៏នៅណុងតែម្តងនឹង

កៈ អូ៎!!នៅណុងទៅកើតបានពូហើយនឹងកូនចៅមកក៏នៅណុងបណ្តោយចឹងទៅ?

ខៈ អូ៎!!បាទចឹងនឹង

កៈ អូ៎!!បាទពូចុះ
សំរាប់ឪពុករបស់ពូនឹងកាលពីគាត់នៅរស់គាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរពូ
នឹងសំរាប់ចិញ្ចឹមក្រុមគ្រួសារហាស?

ខៈ
កាលពីមុនគាត់ជាអ្នកដង្ហៅបឹងដង្ហៅអីចឹងទៅអីចឹងដែរនឹងគាត់អ្នកធ្វើដង្ហៅបឹងដង្ហៅព្រែក
អីនឹង ចិញ្ចឹមកូនរហូតទាល់តែស្រុកកើតសង្គ្រាមនឹងហាស

កៈ អូ៎!!បាទពូបាទប៉ុន្តែគាត់ស្លូតរឺមួយក៏គាត់កាចដែរទៅពូ?

ខៈ ឪពុករបស់ខ្ញុំនឹងគាត់ស្លូតទេនឹង

កៈ អូ៎!!បាទចុះម្តាយរបស់ពូវិញគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរពូ?

ខ៖
គាត់និយាយរួមនឹងគាត់មើលឪពុកគាត់ធ្វើការងារជាមួយឪពុករបស់ខ្ញុំនឹងគាត់ខាងដង្កៅបឹងដង្កៅ អីចឹងដែរនឹងហាស

ក៖ ចឹងប៉ុន្តែម្ដាយរបស់ពូជួយធ្វើការងារឪពុករបស់ពូចឹងទៅ?

ខ៖ បាទនឹងហើយ

ក៖ ចុះគាត់កាចរឺមួយក៏ស្លូតដែរពូម្ដាយរបស់ពូហាស?

ខ៖ ម្ដាយរបស់ខ្ញុំនឹងគាត់ស្លូតនឹងហាសគាត់មិនដែរវៃកូនមិនដែរធ្វើអីកូនទេ

ក៖ អូ៎!!បាទពូ ចុះពូមានចងចាំថាកាលពីឪពុកម្ដាយរបស់ពូនៅរស់ពូ
មានចងចាំអនុស្សាវរីយ៍ធ្លាប់ធ្វើអីគេខ្លះដែរចងចាំអត់ភ្លេចហាសពូ?

ខ៖ ខ្ញុំបើនិយាយរួមទៅខ្ញុំមិនសូវបានធ្វើអីទេពីព្រោះខ្ញុំពៅគេ

ក៖ ពូតូចជាងគេណាពូ?

ខ៖ ខ្ញុំតូចជាងគេនឹងហាសគ្រាន់តែធមដឹងក្ដីឡើងនឹងគាត់ស្លាប់ចោលទៅនឹង

ក៖
អូ៎!!បាទពូចុះឪពុករបស់ពូនឹងគាត់មានដែរប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅពូដែរទេពូ?
ខ៖ គាត់ធ្លាប់ប្រាប់ពីប្រវត្តិដែរនឹងគាត់ប្រាប់ប្រវត្តិស្រុកគាត់ចឹងហាស

ក៖ បាទគាត់ប្រាប់អីគេខ្លះដែរចឹងទៅពូ?

ខ៖ គាត់ថាពីក្មេងនឹងគាត់ប្រឹងរកធ្វើការងារចឹងទៅណាស់
គាត់រុករានដីព្រៃនៅភ្នំប្រសាកភ្នំអីនេះ

ក៖ បាទពូបាទ?

ខ៖
ហើយគាត់ថាធ្លាប់មានក្រពើមានអីនៅក្នុងព្រៃនឹងវាឡើងក្រាំងនៅភ្នំប្រសាកអីគាត់ឧស្សាហ៍ជួប ឧស្សាហ៍អីចឹងហាស

ក៖ អូ៎!!នៅលើគោកចឹងហោសពូ?

ខ៖  បាទនឹងហើយចឹង

ក៖  ម៉េចបានក្រពើនៅលើកគោកអីវិញចឹងពូ?

ខ៖  វាឡើងដេកថ្ងៃអីចឹងហាស

ក៖  អូ៎!!បាទពូបាទ?

ខ៖
ហើយគាត់ថាឃើញអីចឹងជួបពេលខ្លះលួចកាប់មួយអីដែរដល់ពេលកាប់ទៅបាក់កាំបិតបង្គោក គាត់ខានកាប់ព្រៃអីចឹងគេសើចហាសហា

ក៖  អូ៎!!កាប់ក្រពើហោសពូ?

ខ៖  បាទនឹងហើយ

ក៖  កាប់ទៅប៉ុន្តែក្រពើវារឹងហីពូ?

ខ៖  បាទកាប់ក្បាលក្រពើហើយវាបាក់អាក្បាលកាំបិតនឹង

ក៖  អូ៎!!ហូបាទ
ចុះម្តាយរបស់ពូគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីនៅក្មេងទៅពូដែរទេ?

ខ៖  គាត់ពីក្មេងនឹងគាត់ធ្លាប់ប្រាប់ដែរនឹងគាត់អ្នកស្រុកជាមួយឪពុករបស់ខ្ញុំនឹងដែរនឹង

ក៖  បាទពូបាទ?

ខ៖
គាត់គ្មានអីគេគាត់ដើរធ្វើស្រូវព្រុះធ្វើអីចឹងចឹងទៅនៅក្នុប្រសាកអីនៅក្នុងព្រៃជាមួយតារបស់ខ្ញុំចឹង ទៅណាស់

ក៖  បាទពូបាទ?

ខ៖  គាត់ធ្លាប់ប្រាប់ប្រវត្តិចឹងគាត់ប្រាប់ថាគាត់ក៏ជាអ្នកកំសត់ដែរមិនជាអ្នកអីនេះទេ

ក៖  អូ៎!!ចឹងណាពូណា?

ខ៖  គាត់កំព្រីកំព្រា

កៈ ចុះពូយាយតាខាងឪពុកនឹងពូមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ស្គាល់បានខាង ទេស្គាល់បានតា

កៈ ចឹងខាងឪពុកណាពូចុះគាត់មានឈ្មោះអីគេដែរពូ?

ខៈ គាត់មានឈ្មោះតាថោង

កៈ
អូ៎!!ចុះគាត់កើតនៅណាដែរពូមានដឹងទេគាត់នៅកណ្ដាលស្ទឹងនៅដែររឺយ៉ាងណាដែរពូ?

ខៈ គាត់កើតនៅស្រុកគាត់នៅកណ្ដាលស្ទឹងនឹងដែរនឹង

កៈ ចុះយាយតាខាងម្ដាយវិញពូមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ គាត់ឈ្មោះអើរតាឈ្មោះតាហុង

កៈ ចុះយាយវិញពូ?

ខៈ
យាយនឹងខ្ញុំអត់បានស្គាល់ទេម្ដាយរបស់ខ្ញុំនឹងអត់ដែរបានប្រាប់ឈ្មោះទេកំព្រាស្លាប់តាំងពីយូរហើយ

កៈ ចឹងមានន័យថាទាំងខាងម្ដាយនឹងយាយទាំងខាងឪពុកនឹងពូអត់ស្គាល់ទាំងពីរណាពូស្គាល់តែឈ្មោះខាងតាទាំងពិរនឹងហោស?

ខៈ បាទនឹងហើយ

កៈ អូ៎!!បាទពូបាទប៉ុន្តែដូចជាពូមកនៅនឹងយូរនៅពូអស់ប៉ុន្មានឆ្នាំដែរហើយនឹង?

ខៈ ខ្ញុំមកនៅនឹងជាង10ឆ្នាំហើយនឹងមកនឹង

កៈ អូ៎!!បាទពូបាទ?

ខៈ តាំងពីឆ្នាំ2001ហោស

កៈ អូ៎!!ចឹងវាជិត20ឆ្នាំហើយណាពូ?

ខៈ បាទនឹងហើយចឹង

ក៖  ចុះពូមានបងប្អូនរឺមួយក៏កូនចៅណាដែរទៅរស់នៅក្រៅប្រទេសទេពូ?

ខ៖  អត់មានទេមានតែពូនឹងហាស

ក៖  គាត់នៅណាវិញទៅពូ?

ខ៖  គាត់នៅអាមេរិចហោស

ក៖  អូ៎!!គាត់ធ្វើអីគេដែរនៅអាមេរិចដែរពូដឹងអត់?

ខ៖  គាត់ជាអ្នកភាសន៍ខ្លួនពេលសង្គ្រាមនឹងដែរនឹង

ក៖  អូ៎!!ដល់ឥឡូវនឹងពូអត់ដែរដឹងដំណឹងគាត់ទេណ?

ខ៖
ខ្ញុំអត់ដែរដឹងថាលេខកូដគាត់ទេថាគាត់ធ្វើអីគេទេប៉ុន្តែគាត់អាត្រេតហើយឥឡូវនឹងហោស
ដោយសារតែគាត់ចាស់ដែរហើយនឹង

ក៖  អូ៎!!បាទដោយសារតែគាត់ចាស់ដែរហើយនឹង?

ខ៖  បាទគាត់អាយុ80ឆ្នាំជាងហើយនឹង

ក៖  បាទពូបាទ ចុះភរិយារបស់ពូនឹងគាត់មានឈ្មោះអីគេដែរពូ?

ខ៖  គាត់មានឈ្មោះយ៉ន សុខុន

ក៖  ចុះពូមានចងចាំថ្ងៃដែរពូបានរៀបអាពាពិពាហ៍ដែរទេ?

ខ៖  អត់បានចងចាំទេថ្ងៃបើឆ្នាំនឹងចាំ

ក៖  នៅឆ្នាំណាដែរទៅពូ?

ខ៖  ការនៅឆ្នាំ1988

ក៖  ចឹងការនៅឆ្នាំ1988អូបាទពូ
ចុះនៅពេលដែរពូបានរៀបអាពាហ៍ពិពាហ៍ជាមួយមីងនឹងហាស
តើពូជាអ្នកចង់រៀបចំដោយខ្លួនឯង រឺមួយក៏ឪពុកម្តាយជាអ្នករៀបចំអោយដែរពូ?

ខ៖  ឪពុកម្តាយគាត់ជាអ្នករៀបចំអោយម្តាយគាត់ជាអ្នករៀបអោយនឹង

កៈ អូ៎!!បាទពូ ចុះមានជាជំនួនជូនបណ្ណាការអីទៅមីងដែរទេពូ?

ខៈ មានដែរតើ!!

កៈ ប៉ុន្តែមានដូចជាច្រើនដែរទេពូ?

ខៈ កាលណុងវាតិចលុយបើប្រៀបធៀបដល់ឥឡូវនឹងវាតិចៗមែនទែនទៅណាស់ ប៉ុន្តែកាលពីជំនាន់ណុងវាថ្លៃមែនទែននឹងហាស

កៈ អូ៎!!បាទពូត្រូវ
ចុះពូនៅពេលដែរពូចាប់អារម្មណ៍មីងនឹងពូចាប់អារម្មណ៍នៅពេលណាដែរពូ
ហើយដូចជាពូស្គាល់គ្នាប៉ុន្មានឆ្នាំបានពូចូលស្ដីដណ្ដឹងមីងចឹងហាស?

ខៈ
ខ្ញុំកាលណុងនិយាយរួមនឹងខ្ញុំអារឿងស្គាល់នឹងស្គាល់តាំងពីនៅតូចៗដូចគ្នានឹងពីព្រោះនៅក្បែរគ្នា ដែរនឹងហាស
ប៉ុន្តែឪពុកម្ដាយគាត់ជាង្នករៀបចំចឹងទៅបានយើងតាមគាត់ចឹងទៅ

កៈ ចឹងមានន័យថាពូនឹងមីងនៅជាមួយគ្នាទេ នៅស្រុកភូមិជាមួយគ្នាទេ?

ខៈ បាទនឹងហើយ

កៈ ចឹងមានន័យថាចាប់អារម្មណ៍ជាមួយមីងតាំងពីតូចហើយនឹងហោសពូ?

ខៈ បាទនឹងហើយចឹង

កៈ ចុះសំរាប់ពូរៀនបានថ្នាក់ទីប៉ុន្មានដែរទៅពូ?

ខៈ ខ្ញុំរៀនបានតិចហាសពីព្រោះខ្ញុំកូនកំព្រា ខ្ញុំរៀនបានត្រឹមតែថ្នាក់ទី3នឹង

កៈ អូ៎!!ប៉ុន្តែកាលពីពូរៀននឹងពូរៀននៅណាដែរពូ?

ខៈ នៅវត្តរៀននៅសាលាវត្តអំពិល

កៈ វត្តនឹងឈ្មោះវត្តអំពិលចឹងតែម្ដងហោសពូ?

ខៈ បាទវាចឹងតែម្ដងនឹង

កៈ ប៉ុន្តែពូមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេពូ?

ខៈ អត់ទេ

កៈ ដូចជាភាសាវៀតណាម ភាសាថៃអីហាសពូ?

ខៈ កាលពីមុននឹងខ្ញុំចេះដែរភាសាវៀតណាមអីដែរនឹងឥឡូវនឹងខ្ញុំបានភ្លេចអស់ហើយនឹងតាំងពីខ្ញុំមកនៅស្រុកនឹងខ្ញុំនៅឆ្ងាយពីវៀតណាមហាស

កៈ ដោយសារតែពូខាន់ប្រើវាយូរដែរហើយណាពូ?

ខៈ បាទនឹងហើយបាទ

កៈ ចុះពូធ្លាប់មានមិត្តភក្តិដែរស្និទ្ធស្នាលធំធាត់មកជាមួយគ្នាដែរទេកាលពូនៅរៀនហាស?

ខៈ ធ្លាប់មានដែរនឹង

កៈ ប៉ុន្តែដូចជាមានច្រើនដែរទេពូ?

ខៈ មិនមានច្រើនទេប្រហែលជាមាន3-4នាក់នឹងអានឹងជិតស្និទ្ធនឹងតែម្តងនឹងហាស?

កៈ បាទប៉ុន្តែពូនៅចងចាំឈ្មោះពួកគាត់ដែរទេពូ?
ខៈ ខ្ញុំចងចាំតើ!!

កៈ ពួកគាត់មានឈ្មោះអីគេខ្លះដែរទៅពូ?

ខៈ អាមួយនឹងមានឈ្មោះផុន ប៉ុន្តែឥឡូវនឹងសព្វថ្ងៃវានៅជើងឯកនេះ

កៈ អូ!!ចឹងនៅជិតពូដែរណាពូ?

ខៈ ហើយនឹងមានឈ្មោះអាគុណាក់ នឹងមានឈ្មោះអារី នឹងអ្នកជិតស្និទ្ធនឹងមានតែប៉ុណ្ណឹង

កៈ បាទពូ ចុះពូមានចងចាំអនុស្សាវរីយ៍កាលពីនៅក្មេងៗហាស
តើពូធ្លាប់បានធ្វើអីគេជាមួយពួកគាត់ខ្លះដែរទៅពូ?

ខៈ គ្មានអីទេធ្លាប់តែដើរលេងមើលល្ខោនធ្វើអីមកវិញដេកតាមវាលស្រែអត់ងងុយនឹងដល់ពេលដែរអត់ងងុយពេកនឹងដេកតាមច្រាំងវាលស្រែអីនឹង

កៈ អូ!!បាទពូ ចុះមានធ្លាប់ទៅស្រែលេងអីជាមួយពួកគាត់ដែរទេពូ?

ខ៖ ធ្លាប់ដែរនឹងទៅច្រូតស្រូវទៅអីជាមួយគ្នានឹងហាស

ក៖ អូ៎!!បាទពូ ធ្លាប់បានទៅរកត្រីអីជាមួយគ្នាដែរមែនទេពូ?

ខ៖ បាទនឹងហើយធ្លាប់

ក៖
ចុះពូគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូធ្លាប់បានធ្វើការងារអីគេខ្លះដែរទៅពូ?

ខ៖ ខ្ញុំតាំងពីក្មេងមកនឹងខ្ញុំធ្វើស្រូវហើយនឹងធ្វើជាកម្មករគេនឹងដូចជាសំណង់
ដល់កក្រោយមកនៅឆ្នាំ2001នឹងខ្ញុំមកនៅយើងស្ទឹងជ្រៅនេះ

ក៖ បាទពូបាទ?

ខ៖ ខ្ញុំដាំត្រកួនដាំអីនឹងជាការងាររបស់ខ្លួនឯងតែម្តងនឹងហាស

ក៖ អូ៎!!បាទពូត្រូវហើយនឹងហាស
ចុះសំរាប់ពូគិតថាពូធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរណាពូ?

ខ៖ បាទធ្លាប់ដែរតើនឹង

ក៖ ប៉ុន្តែការងារនឹងពូធ្លាប់ធ្វើជាលក្ខណៈការងារអីគេខ្លះដែរទៅពូ?

ខ៖ វាលស្រែធម្មតាអានឹងមានអីមានតែយើងភ្ជួរហើយនឹងយើងស្ទូងអីនឹង

ក៖ បាទពូបាទនឹង?

ខ៖ ច្រូតស្រូវអីនឹងហាស

ក៖ ចុះពូធ្លាប់បើកអាជីវកម្មលក់ដូរអីទេពូ?

ខ៖ ខ្ញុំអត់ដែរមានផងនឹង

ក៖ ចុះពូមានធ្លាប់ចិញ្ចឹមជាសត្វ ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមគោ ចិញ្ចឹមក្របីអីទេពូ?

ខ៖ នឹងធ្លាប់មានគោ ក្របី ជ្រូក

ក៖ ប៉ុន្តែពូចិញ្ចឹមលក្ខណៈជាខ្នាតធំ រឺមួយពូចិញ្ចឹមលក្ខណៈជាគ្រួសារដែរពូ?

ខ៖ ខ្ញុំចិញ្ចឹមលក្ខណៈជាគ្រួសារតិចតួចនឹងហាស

កៈ អូ៎!!បាទពូ ចុះពេលណុងពុមានចិញ្ចឹមអីគេខ្លះដែរទៅពូ?

ខៈ ខ្ញុំចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ គោក្របីអីនឹងធ្លាប់មានចិញ្ចឹមដែរនឹង

កៈ អូ៎!!បាទពូ ចុះពុគិតថាជីវិតរបស់ពូតាំងពីក្មេងរហូតមកដល់ពេលនេះ តើពូគិតថាមានការផ្លាស់ប្តូរអីគេដែរទៅពូ?

ខៈ វាមានការផ្លាស់ប្តូរដែរនឹងពីមុននឹងមកវាមានការផ្លាស់ប្តូរតិចតួចដែរនឹង វាមិនមានការផ្លាស់ប្តូរអីច្រើនប៉ុន្មានទេ

កៈ បាទពូ ចុះពូគិតថាជីវភាពរបស់ពូសព្វថ្ងៃនឹងគ្រាន់ជាងមុនដែរឺយ៉ាងម៉េចដែរពូ?

ខៈ វារៀងគ្រាន់ជាងមុនដែរ វាមិនសូវពិបាកដូចពីមុនមកនឹង

កៈ អូ៎!!បាទពូត្រូវហើយនឹងពូ?

ខៈ បាទនឹងវាចឹង

កៈ ចុះពូគិតថាពូចូលចិត្តពិសារម្ហូបអីគេដែរទៅពូ?

ខៈ ខ្ញុំរាល់ថ្ងៃនឹងបើត្រីអីនឹងចូលចិត្តអាំងអីនឹងហាស

កៈ អូ៎!!ចូលចិត្តអាំងត្រីចុចជាមួយស្វាយអីចឹងហោសពូ?

ខៈ បាទៗៗនឹងហើយ

កៈ ចុះគិតថាល្បែងប្រជាប្រិយ៍អីគេដែរពូគិតថាពូចូលចិត្តលេងហាសពូ?

ខៈ បើល្បែងប្រជាប្រិយ៍អីនឹងចូលចិត្តលេងច្រៀង រាំអីនឹងហាសនឹងចូលចិត្ត

កៈ ចុះលក្ខណៈថាល្បែងចោលឈូង ទាញព្រាត លាក់កន្សែង បោះអង្គុញ ស្តេចចង់ដណ្តើមស្លឹកឈើអីពូចូលចិត្តដែរទេ?

ខៈ អានឹងធ្លាប់បានលេងដែរនឹងកាលពីក្មេងអីនឹង ដល់ពេលឥឡូវនឹងយើងចាស់ហើយ

កៈ បាទពូបាទចឹង?

ខៈ យើងគ្រាន់តែឈរមើលក្មេងៗៗលេងអីចឹងទៅ

កៈ ចុះពូចូលចិត្តច្រៀងទេពូ?

ខ៖ ពីមុននឹងចូលចិត្តដែរនឹងប៉ុន្តែឥឡូវនឹងវាចាស់ហើយចឹងចេះតែខ្មាស់គេនឹង

ក៖ ប៉ុន្តែភាគច្រើននឹងពូចូលចិត្តច្រៀងបទអីគេដែរទៅពូ
ពូអាចប្រាប់ចំណងជើងមួយពីរអីក៏បានដែរ?

ខ៖ សម្រស់កុះកុងអីចឹងទៅ

ក៖ អូ៎!!បទពីដើមណាពូ?

ខ៖ បាទនឹងហើយ

ក៖ ប៉ុន្តែឥឡូវនឹងពូនៅតែចូលចិត្តស្តាប់បទចំរៀងដែររឺមួយយ៉ាងម៉េចដែរពូ?

ខ៖ ខ្ញុំនៅតែចូលចិត្តស្តាប់ហើយអោយតែលឺគេចាក់នៅតែចូលចិត្តស្តាប់ដែរចឹងហាស បទសម័យឥឡូវនឹងស្តាប់ដែរតែវាមិនសូវដុចពីដើមសម័យមុនអីហាស

ក៖ បាទពូបាទ?

ខ៖ អើរក្មេងៗគេពិរោះទាន់សម័យអីចឹងទៅណាស់

ក៖ បាទពូ ប៉ុន្តែពូចូលចិត្តស្តាប់ល្ខោនយីកេអាយៃអីដែរតើហីពូ?

ខ៖ ខ្ញុំចូលចិត្តល្ខោនអាយៃ នឹងចាបីនឹង

ក៖ អូ៎!!បាទពូ
ចុះពុធ្លាប់មាននរណាគេនៅក្នុងក្រុមគ្រួសាររបស់ពូចេះលេងឧបករណ៍ភ្លេងដែរទេពូ?

ខ៖
ពីមុនមកនឹងបងរបស់ខ្ញុំនឹងគាត់ធ្លាប់លេងដែរលេងខាងកាន់ហ្គីតាអីនឹងខ្ញុំក៏ធ្លាប់កាន់លេង ដែរនឹង

ក៖ ប៉ុន្តែលក្ខណះថាភ្លេងខ្មែរ ភ្លេងពិនពាត អកកេះ អកកណ្តុងអីចឹងហាសមានទេពូ?

ខ៖ អកកេះពីមុនមកនឹងបងខ្ញុំធ្លាប់លេងដែរគាត់កាន់ខាងហ្គីតា

ក៖ អូ៎!!ចឹងហោសពូ?

ខ៖ ខ្ញុំក៏លេងដែរពីមុនមកនឹង

កៈ ពូលេងហ្គីតាដែរមែនពូ?

ខៈ លេងហ្គីតាហើយនឹងស្គរ
ប៉ុន្តែឥឡូវនឹងលេងលែងកើតហើយនឹងវាគាំងដៃគាំងជើងហើយនឹង

កៈ បាទពូដោយសារតែយើងចាស់ហើយខានលេងយូរដែរហើយណាពូ?

ខៈ ខានលេងយូរដែរហើយនឹង

កៈ ចុះផ្ទះរបស់ពូកាលពីក្មេងនឹងផ្ទះរបៀបម៉េចដែរពូ?

ខៈ ខ្ញុំពីក្មេងមកនឹងផ្ទះស្បូវ

កៈ អូ្ហ!!ផ្ទះស្បូវណាពូ ប៉ុន្តែលក្ខណះថាជញ្ជាំងឈើអីដែរណាពូ?

ខៈ ជញ្ជាំងកាលណុងជញ្ជាំងស្លឹកត្នោត

កៈ អូ្ហ!!ជញ្ជាំងស្លឹកត្នោតណាពូ?

ខៈ បាទនឹងចឹង

កៈ ចុះនរណាគេជាអ្នកសាងសងផ្ទះរបស់ពូកាលពីនៅក្មេងដែរហាសពូ?

ខៈ នៅក្មេងនឹងឪពុកម្ដាយរបស់ខ្ញុំនឹង

កៈ អូ្ហ!!ចឹងហោសពូ ?
ខៈ បាទនឹងហើយចឹង

កៈ អូ្ហ!!ប៉ុន្តែពួកគាត់ចេះធ្វើផ្ទះដែរទេពូ?

ខៈ គាត់អើរបើលក្ខណះថាតូចតាចគាត់ចេះប៉ុន្តែលក្ខណះធំដុំអីគាត់អត់ចេះទេ

កៈ ប៉ុន្តែពូចេះធ្វើផ្ទះដែរទេ?

ខៈ ខ្ញុំបានតែតូចតាចចឹងដែរនឹងហាស
ដូចថាយើងធ្វើលក្ខណះតូចតាចយើងនៅខ្លួនយើងចឹងហាស

កៈ ដូចថាផ្ទះប៉ុណ្ណឹងអីពូអាចធ្វើបានមែនទេពូ?

ខៈ បាទចេះធ្វើនឹង

កៈ ប៉ុន្តែនរណាគេបានបង្រៀនអោយពូចេះធ្វើដែរពូ?

ខៈ អានឹងបើនិយាយពីអ្នកដែរបង្រៀននឹងអត់មានទេ ប៉ុន្តែបើនៅស្រុកវិញគេរកទៅជួយចឹងយើងចេះតែ យើងចេះតែទៅជួយគេចឹងទៅណាស់

កៈ អូ៎!!យើងធ្វើចឹងយើងចេះណាពូ?

ខៈ បាទចឹងយើងចេះធ្វើ

កៈ អូ៎!!បាទពូ ចុះពូគិតថាជំនាញអីដែរពុចេះស្ទាត់ជំនាញដែរពូ?

ខៈ អើរអារឿងចេះជំនាញនឹងអត់មានទេក្មួយអើយ

កៈ ចុះលក្ខណៈថាពូដោយសារតែពូនៅស្រុកទន្លេចឹងពូលក្ខណៈធ្វើស្រែរឺនេសាទត្រីដែរពូចេះជំនាញ ចឹងហាសពូ?

ខៈ នឹងមានត្រីអានឹងរៀងគ្រាន់បើដែរចឹងហាស

កៈ អូ៎!!ចឹងហោសពូ?

ខៈ បាទហើយធ្វើស្រែនឹងវាជំនាញហើយនឹង

កៈ អូ៎!!នឹងពូជំនាញហើយណាពូ?

ខៈ បាទនឹងហើយជំនាញធ្វើស្រែនឹងហាស

កៈ ចុះលក្ខណៈថាវេញវល្លិ៍ ធ្វើកន្ទេល ធ្វើផ្តៅ កូរស្ករត្នោតនឹងពូចេះដែរទេ?

ខៈ អត់មានផងនឹង

កៈ ប៉ុន្តែពូធ្លាប់បានឡើងដើមត្នោតដែរទេពូ?

ខៈ ត្នោតនឹងអត់ដែរបានឡើងផងនឹងកាលណុងវាញ័រជើងនឹង

កៈ ប៉ុន្តែពូអត់ដែរបានឡើងទេណាពូ?

ខៈ បាទអត់ដែរផងគ្រាន់តែសាកមើលត្រឹមមួយម៉ែត្រនឹងឡើងបែកញើសបាត់ទៅហើយនឹង

កៈ  អូ៎!!ចឹងមានន័យថាពូខ្លាចខ្ពស់ដែរហើយពូ?

ខៈ  បាទខ្លាចដែរតើ!!

កៈ  អូ៎!!បាទ ចុះពូគិតថាពូអាចប្រាប់ខ្ញុំថាពូលំបាកពេលណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស ពូធ្លាប់មានការលំបាកអីគេខ្លះដែរទៅពូ?

ខៈ  និយាយរួមនឹងវាលំបាកកាលមុននឹងលំបាកការរត់សង្គ្រាមអីចឹងហាស

កៈ  អូ៎!!ចឹងហោសពូ?

ខៈ  លំបាកគេចគ្រាប់ពីពលពតអីចឹងវាធ្វើបាបយើងណាស់ដែរនឹង

កៈ  ប៉ុន្តែកាលពីជំនាន់លុនណុលនឹងពូគេអោយធ្វើអីគេដែររឺមួយពេលណុងមានសង្គ្រាមធម្មតាទេពូ?

ខៈ  គ្រាន់តែយើងគ្មានបានធ្វើអីទេអានឹងគ្រាន់តែយើងគេចអាគ្រាប់គេនឹងបាញ់គ្នាគេនឹងអាយើងនឹង លំបាកក្រាបលូនគ្មានបានដេកបានពួនទេ

កៈ  បាទពូបាទ ចុះកាលពីជំនាន់ពលពតនឹងពូគិតថាពូមានការលំបាកអីគេខ្លះដែរទៅពូ?

ខៈ  ជំនាន់ពលពតនឹងបើនិយាយពីការលំបាកនឹងគេអោយទៅធ្វើការរែកដីអីតូចៗនេះគេអោយរែកដី ដូចថាគេសែងដីអីចឹងទៅណាស់

កៈ  បាទពូបាទ?

ខៈ  ហើយបាយនឹងក៏គេមិនបានអោយយើងហូបគ្រប់គ្រាន់ដែរលេងបបរ លេងវាលវែកនឹងយើងហូបនឹង មានដែរឆ្អែតណា

កៈ  ប៉ុន្តែកាលពីជំនាន់ណុងពូអាយុប៉ុន្មានដែរពូ?

ខៈ  ខ្ញុំប្រហែលជាអាយុត្រឹម12-13ឆ្នាំអីនឹងមើលទៅ

កៈ អូ៎!!ប៉ុន្តែពេលណុងពូនៅកងកុមារនៅឡើយរឺមួយយ៉ាងម៉េចដែរពូ?

ខៈ ខ្ញុំនៅកងកុមារប៉ុន្តែគេដាក់នៅក្នុងកងកុមារពិសេស

កៈ អូ៎!!នៅកងកុមារពិសេសហោសពូ?

ខៈ បាទនឹងហើយ

កៈ អូ៎!!បាទពូ ចុះពេលណុងគេជំលាសពូទៅណាដែរទៅពូ?

ខៈ ខ្ញុំបើនិយាយទៅគេជំលាសនៅក្នុងស្រុកដែរនឹងហាស

កៈ ប៉ុន្តែទៅភូមិផ្សេងៗ?

ខៈ ប៉ុន្តែគ្រាន់តែនៅភូមិផ្សេងនឹងហាស

កៈ ចុះទៅនឹងលក្ខណះថាពូទៅជាក្រុមគ្រួសារតែម្តងនឹងរឺមួយពូទៅតែម្នាក់ឯងទេនឹង?

ខៈ ខ្ញុំទៅជាក្រុមគ្រួសារតែម្តងនឹងហាសគេអោយយើងទៅនឹងគេអត់ធ្វើបាបយើងទេ ប៉ុន្តែបើប្រជាជនថ្មីវិញគេធ្វើបាបហាសគេបញ្ជូនយកទៅបាត់ៗតែម្តងនឹងហាស ប៉ុន្តែចឹងខ្ញុំជាប្រជាជនចាស់ទេដែរគេអោយនៅនឹងហាស

កៈ អូ៎!!ប៉ុន្តែកន្លែងធ្វើការងារនឹងនៅកន្លែងផ្សេងគ្នាទាំងអស់មែនទេពូ?
ខៈ បាទកន្លែងធ្វើការងារនឹងនៅផ្សេងគ្នាទាំងអស់នឹង

កៈ ចុះម្តាយឪពុករបស់ពូនឹងគេអោយធ្វើអីគេដែរទៅពេលណុងហោសពូ?

ខៈ កាលណុងគាត់ចាស់ដល់ពេលចឹងគេអោយគាត់ដាំបន្លែអីចឹងទៅណាស់

កៈ អូ៎!!បាទពូបាទ?

ខៈ ហើយម្តាយរបស់ខ្ញុំនឹងគេអោយលាងចាននៅក្នុងរោងបាយ

កៈ ចុះបងៗរបស់ពូវិញគេអោយធ្វើអីគេដែរទៅ?

ខៈ គាត់កងចល័តខាងរែកដីនឹង ខាងស្ទូងស្រូវអីចឹងទៅណាស់

កៈ ពូរែកដីដែរនឹង?

ខ៖
ខ្ញុំរែកដីដែរប៉ុន្តែជំនាន់កាលណុងគេអោយយើងសែងទេគេមិនដាក់អោយយើងរែកពេកទេណាស់

ក៖ ប៉ុន្តែមានច្រើនគ្នាសែងពីរបីនាក់ចឹងហោសពូ?

ខ៖ បាទៗៗសែងពីរទៅបីនាក់ចឹងទៅ

ក៖ ប៉ុន្តែរបបអាហារអីយើងញាំុអត់គ្រប់គ្រាន់ដែរទេណាពូ?

ខ៖ បាទរបបអាហារនឹងអត់គ្រប់គ្រាន់ទេនឹងជំនាន់ណុង

ក៖ ប៉ុន្តែគេមានជំលាសក្រុមគ្រួសាររបស់យើងទៅណាផ្សេងទៅណាទៀតទេពូ?

ខ៖ អត់មានទេ

ក៖
ចឹងមានន័យថានៅតែក្នុងភូមិណុងហើយធ្វើការងារទាល់តែដាច់ពលពតនឹងតែម្តងហោសពូ?

ខ៖ បាទទាល់តែចេញពីពលពតណុងបានបកទៅស្រុកវិញ
អើរគេជំលាសដែរប៉ុន្តែគេជំលាសបន្តិចបន្តួច ចឹងហាសគ្រាន់តែខុសឃុំគ្នាហាស

ក៖
បាទពូបាទហើយរហូតទាល់តែដាច់ពលពតនឹងពូគិតថាពូមានធ្លាប់ជួបការលំបាកអីផ្សេងទៀតទេពូ ដោយសារតែដាច់ពលពតនឹងពេលណុងយើងត្រូវការរកលុយរកអីហើយណាពូ?

ខ៖ លំបាកជំនាន់ណុងបែកពីពលពតនឹងម្នាក់ៗៗបាតដៃទទេនឹងអត់មានអីទេណាស់

ក៖ បាទពូ ប៉ុន្តែកាលពីបែកពលពតនឹងពូនៅអាយុប៉ុន្មានដែរពូ អាយុប្រហែលជា15-16ឆ្នាំហើយណាពូ?

ខ៖ បាទប្រហែលជាប៉ុណ្ណឹង

ក៖ ប៉ុន្តែគេមានចាប់អោយយកទៅធ្វើជាទាហ៊ានអីទេពូ?

ខ៖ 
អារឿងចាប់នឹងគេចាប់ដែរនឹងហាសប៉ុន្តែខ្ញុំចេះតែគេចហើយម្យ៉ាងទៅខ្ញុំហើយនឹងបងរបស់ខ្ញុំនឹងវា រៀងឆ្លាតដែរចឹងហាស

ក៖ បាទពូបាទចឹង?

ខ៖ 
មើលតែគេចង់មកចាប់អីនឹងមិនស្រួលៗនឹងហៅបងរបស់ខ្ញុំទៅផឹកស៊ីអីចឹងទៅស្គាល់ជាពួកម៉ាក់ អីចឹងទៅគេមិនសូវជាធ្វើបាបយើងចឹងទៅណាស់

ក៖ អូ្ន!!បាទពូប៉ុន្តែខ្ញុំលឺថាអ្នកខ្លះនឹង
គ្រាន់តែឃើញគេមកចឹងគេបានលោតពីលើផ្ទះយ៉ាងម៉េចហោសពូ?

ខ៖ បទលោតដែរនឹងមើលតែជួបអ្នកដែរមិនស្គាល់ដែរនឹងខ្ញុំគេពាត់ជាប់ពីរបីសារដែរនឹង
ប៉ុន្តែប្រពន្ធរបស់ខ្ញុំនឹងចេះតែគំរាមដាក់កាំបិតក្បែរខ្លួនចឹងទៅគេមិនហ៊ានឡើងនឹង

ក៖ អូ្ន!!ប៉ុន្តែពេលណុងពូមានគ្រួសារហើយណាពូ?

ខ៖ បាទមានហើយនឹង

ក៖ ប៉ុន្តែពូមានគ្រួសារនៅឆ្នាំ1988ហីពូ?

ខ៖ បាទនឹងហើយ

ក៖ បាទពូនៅឆ្នាំ1988ចុះពេលណុងបានគេឈប់ចាប់យកទៅធ្វើជាទាហ៊ានអីចឹងហាសពូ?

ខ៖ កាលណុងដូចជាឆ្នាំ1991មិនដឹងឆ្នាំ1990មិនទេនេះខ្ញុំភ្លេចដែរហើយកាលណុង

ក៖ ល្មមគេឈប់ចាប់ណាពូ?

ខ៖ បាទល្មមគេឈប់ចាប់

ក៖ ប៉ុន្តែគេចាប់យើងយកទៅណាដែរពូ?

ខ៖ គេយកទៅធ្វើជាទាហ៊ានអីនឹង

ក៖ គេយកទៅធ្វើជាទាហ៊ាននៅណាដែរពូ?

ខ៖ ហ៎!!គេថាជូនទៅព្រៃៗនឹងចំណែកខ្ញុំមិនបានដឹងទេខ្ញុំមិនដែរស្គាល់នឹងគេដែរនឹង

ក៖ ចឹងពូមិនដែរបានទៅទេ?

ខ៖ ខ្ញុំមិនដែរបានទៅចឹងចេះតែខ្លាចគេគេរហូតចឹងទៅ

ក៖ ចុះបងប្អូនរបស់ពូនឹងគេមានចាប់បានយកទៅធ្វើជាទាហ៊ានអីទេពូ?

ខ៖ គាត់កាលណុងមួយជំនាន់ណុងអត់មានទេ
ប៉ុន្តែមានបងប្រុសមួយដែរគេអោយទៅធ្វើជាពលករ ហើយបើបងគេបង្អស់នឹងគាត់
ហើយនឹងបងទីពីរនឹងគាត់ធ្វើទាហ៊ាននៅក្នុងស្រុកដែរហាស

ក៖ បាទពូបាទ?

ខ៖ គាត់ធ្វើការនៅក្នុងទាហ៊ានស្រុកទាហ៊ានអីដែរនឹងហាស

ក៖ រហូតទាល់តែដាច់ពីហ៊ានអីនឹងដល់ឆ្នាំ1991-1992-
1993អីនឹងសន្តិភាពហើយស្រុកយើងណាពូ?

ខ៖ បាទៗៗសន្តិភាពហើយស្រួលហើយនឹង

ក៖ ចុះពេលណុងពូចាប់ផ្តើមធ្វើអីគេរកស៊ីគេដែរទៅពូ?

ខ៖ ជំនាន់ណុងខ្ញុំធ្វើស្រូវហើយ រួចពីខែធ្វើស្រូវអីចឹងទៅខ្ញុំមកភ្នំពេញអីចឹងទៅ

ក៖ អូ៎!!បាទពូ ពេលណុងចាប់ផ្តើមធ្វើស្រែធ្វើស្រូវសំរាប់ចិញ្ចឹមក្រុមគ្រួសារហើយណាពូ?

ខ៖ បាទ!!អានឹងដូចថាយើងនឹងចឹងហើយយើងអាចដើររកការងារបានខ្លះៗ

ក៖ បាទពូបាទ ចុះសំរាប់ពូគិតថាពូឆ្លងកាត់ឧបសគ្គនឹងដោយរបៀបម៉េចដែរពូ?

ខ៖
ការឆ្លងណុងវាយើងមកធ្វើការងារនឹងយើងវាកំសត់ដែរនឹងហាសមករកការងារធ្វើចឹងទៅជូនទៅនឹង
ប៉ុន្តែកាលពីមួយជំនាន់មានផ្ទះអ្នកនៅភ្នំពេញតូចតាចដែរមានមួយជំនួនយើងស្គាល់ចឹងទៅ
ហើយសុំដេកដែរចឹងទៅណាស់

ក៖ អូ៎!!បាទពូបាទ នឹងជាការជំនះនៃការលំបាកដែរពូបានឆ្លងកាត់នៅឧបសគ្គហើយណាពូ?

ខ៖  បាទនឹងហើយចឹង

ក៖  បាទពូ
ចុះពេលណាដែរពូគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់ពូដែរទៅពូ?

ខ៖
វាចំណាស់នេះហើយខ្ញុំវាមិនទាន់ហួសថាបានសប្បាយទេនឹងពីព្រោះចាស់ទៅហើយនឹង

ក៖  អូ៎!!បាទពូ ចុះពូគិតថានៅពេលដែរពូបានការនឹងពូគិតថាពេលណុងសប្បាយទេពូ?

ខ៖  បើការយើងសប្បាយចុះយើងនៅក្មេងហោស

ក៖  បាទចុះពូគិតថាកូនរបស់ពូនឹងបានរៀបចំគ្រួសារខ្លះដែរនៅពូ?

ខ៖  រៀបចំអស់បាន4នាក់នឹងទៅ5នាក់ដែរនឹង

ក៖  ចុះពូគិតថាពេលការកូនអីនឹងពូគិតថាសប្បាយដែរទេ ពេលដែរការពួកគាត់ហាស?

ខ៖  ការណុងសប្បាយ គេមានអកកេះអកអី គេមានអកកណ្តុងអីគេរាំ

ក៖  អូ៎!!បាទពូបាទ?

ខ៖  សប្បាយដែរនឹងក្មេងៗ

ក៖  ចុះពូគិតថាកាលពីក្មេងហាស
កាលពីពូនៅរៀនហាសពូមានធ្លាប់គិតថាពេលដែរពូធំឡើងនឹងពូចង់ធ្វើអីគេមួយដែរទេ?

ខ៖
វាអានឹងសង្ឃឹមថាចង់តែធ្វើការងារទេដូចថាចង់ធ្វើជាប៉ូលីសអីនឹងគេដែរនឹងហាសនៅជំនាន់ណុង ហើយដល់ពេលដែរខ្ញុំវាឪពុករបស់ខ្ញុំនឹងគាត់ស្លាប់អីចឹងទៅ
អត់មាននរណាធ្វើស្រែហើយម្តាយក៏ចាស់ទៀត

ក៖  អូ៎!!ចឹងហោសពូ?

ខ៖  ហើយចឹងមានតែឈប់បង្ខំចិត្តឈប់រៀនហើយធ្វើស្រែធ្វើអីចឹងទៅណាស់

ក៖  អូ៎!!បាទពូបាទ?

ខៈ គ្មាននរណាគេឃ្វាលគោឃ្វាលក្របីអីម្នាក់ឯងហើយក្មួយៗនឹងវានៅតូចៗពេកចឹងបានធ្វើម្នាក់ឯងចឹងទៅ

កៈ បាទពូបាទ
ចុះពូគិតថាសំរាប់បើសិនជាចង់អោយពូផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗហាស
តើពូគិតថាចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរពូ?

ខៈ ចង់ផ្ដែផ្ដាំក្មួយៗនឹងចៅៗជំនាន់ក្រោយអីនឹង អោយប្រឹងតស៊ូចឹងទៅហើយនឹងប្រឹងរៀនអោយបានចំនេះដឹងខ្ពង់ខ្ពស់ទៅ
កុំអោយបែទ្បេរីមួយក៏អោយប៉ះថ្នាំញៀនអីចឹងហាសណាស់

កៈ បាទពូបាទ?

ខៈ ដូចថាខ្ញុំចាស់ជំនាន់មុនខ្ញុំបានឆ្លងកាត់ឧបសគ្គច្រើនជំនាន់ចឹងខ្ញុំដឹងអស់ហើយនឹង
ហើយសម័យឥឡូវនឹងទូលាយហើយខំប្រឹងប្រែងកុំសេពគប់គ្រឿងញៀនអីចឹងទៅ
នឹងជួយកសាងប្រទេសជាតិអីនឹងហាស

កៈ បាទពូបាទ នឹងគ្រាន់តែពូចង់អោយពួកគាត់ជៀសវៀងនឹងហោសពូ?

ខៈ បាទខ្ញុំផ្ដាំផ្ញើរតែប៉ុណ្ណឹងទេនឹង

កៈ ចុះពូមានអីដែរចង់ផ្ដាំផ្ញើរអីផ្សេងទៀតទេពូ?

ខៈ អត់មានអីទេគ្រាន់តែអោយក្មួយៗជំនាន់ក្រោយ
នឹងក្មេងៗជំនាន់ក្រោយនឹងចៅៗជំនាន់ក្រោយ នឹងកុំអោយតែសេពគ្រឿងញៀនអី
កុំអោយតែឃើញមានអាចោរកម្មអីឃើញគេយកទៅធ្វើបាបអីនឹង
ធ្វើទារុណកម្មអីពេលខ្លះមិនទាន់ទៅដល់ប៉ូលីសផងគេវៃសន្លប់ទ្រុឌទ្រោមទៅហើយនឹង

កៈ បាទពូចឹងមានអីផ្សេងពីនឹងទៀតទេពូ?

ខៈ ខ្ញុំអស់ហើយនឹង

កៈ បាទពូ
ចឹងជាចុងក្រោយខ្ញុំសូមអរគុណច្រើនពូដែរបានអោយខ្ញុំពិភាក្សាជាមួយពូដែរទាក់ទងពីប្រវត្តិ

របស់ពូហើយនឹងខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយពូ ដែរចឹងហាសពូ?

ខ៖ បាទៗៗនឹងហើយ

ក៖ បាទចឹងជាចុងក្រោយខ្ញុំអរគុណច្រើនពូ ហើយនឹងខ្ញុំជូនពរពូអោយអាចរកស៊ីមានបាន ហើយនឹងមានសុភមង្គលនៅក្នុងក្រុមគ្រួសារដែរចឹងហាសពូ
បាទចឹងអរគុណច្រើនពូ៕៕៕